## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការក្រសួងយុត្តិធម៌**
លេខ ០១.កយ.សរ-២០០៥

## សារាចរ
## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**<u>ផ្ញើចំពោះ</u>**

លោកស្រីប្រធានតុលាការខេត្ត ក្រុង

លោកស្រីព្រះរាជអាជ្ញាអមតុលាការខេត្ត ក្រុង

**<u>សូមជ្រាប។</u>**

**<u>កម្មវត្ថុ:</u>** អំពីសេចក្តីណែនាំស្តីពីនីតិវិធីជូនដំណឹងពីសាលក្រមកំបាំងមុខ និងការប្រគល់ដីកាកោះ ។
**<u>យោង:</u>** មាត្រា ១១៦ និង មាត្រា ១១៩ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ

សារាចរលេខ០៤ សរ-៩៤ ចុះថ្ងៃទី២២-១១-១៩៩៤ ស្តីពីនីតិវិធីប្តឹងទាស់ និងបណ្តឹងឧទ្ធរណ៍របស់គូក្តី ចំពោះសាលក្រមតុលាការខេត្ត-ក្រុង របស់ក្រសួងយុត្តិធម៌ ។

ខ្ញុំសូមជម្រាបលោក-លោកស្រីជ្រាបអំពីការជូនដំណឹងពីសាលក្រមកំបាំងមុខក្នុងរឿងព្រហ្មទណ្ឌ ក៏ដូចជារឿងរដ្ឋប្បវេណី ដល់គូក្តីដែលមិនបានចូលខ្លួនមកចំពោះមុខតុលាការនៅពេលសវនាការ មានចែងត្រង់មាត្រា១១៦ និង១១៩ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌរួចហើយ ប៉ុន្តែពុំបានល្អិតល្អន់តាមសភាពជាក់ស្តែងដែលកើតមាននៅកម្ពុជាយើងនៅឡើយ ។ ហេតុដូច្នេះហើយបានជាក្រសួងយុត្តិធម៌ បានធ្វើសេចក្តីណែនាំបន្ថែមទៀតតាមសារាចរលេខ០៤ ចុះថ្ងៃទី២២-១១-១៩៩៤ របស់ក្រសួងយុត្តិធម៌ ស្តីពីនីតិវិធីប្តឹងទាស់ និងបណ្តឹងឧទ្ធរណ៍របស់គូក្តី ចំពោះសាលក្រមតុលាការខេត្ត-ក្រុង ដែលមានខ្លឹមសារបញ្ជាក់ថា តុលាការខេត្ត-ក្រុងត្រូវធ្វើយ៉ាងណាជូនដំណឹងអំពីសាលក្រមកំបាំងមុខនោះឱ្យបានដល់គូក្តីហើយប្រាប់គូក្តីឱ្យយល់អំពីសិទ្ធិរបស់គេ ដើម្បីឱ្យគេអាចចូលមកប្តឹងតវ៉ាទាន់ពេលវេលា ។ ប៉ុន្តែករណីនេះក្រសួងយុត្តិធម៌នៅតែបានទទួលពាក្យបណ្តឹង អំពីចំណាត់ការរបស់តុលាការ ដែលបានសម្រេចសេចក្តីហើយតែភាគីមិនបានទទួលលិខិតជូនដំណឹងអ្វីទាំងអស់។ ដើម្បីជៀសវាងការបាត់បង់ប្រយោជន៍ដល់គូក្តីនិងដើម្បីធានាតម្លាភាពរបស់តុលាការក្នុងការអនុវត្តច្បាប់ ក្រសួងយុត្តិធម៌សូមធ្វើការណែនាំបន្ថែម និងកំណត់ជាគោលការណ៍សម្រាប់តុលាការអនុវត្តដូចតទៅៈ

### <u>I-អំពីការជូនដំណឹងពីសាលក្រមកំបាំងមុខ</u>

នៅពេលជំនុំជម្រះ ភាគីដែលត្រូវបានតុលាការកោះអញ្ជើញត្រឹមត្រូវហើយតែភាគីនោះមិនបានចូលខ្លួនតាមការកោះអញ្ជើញរបស់តុលាការទេ ហើយត្រូវបានតុលាការសម្រេចសេចក្តីកំបាំងមុខ តុលាការត្រូវបញ្ជូនសេចក្តីជូនដំណឹងពីសាលក្រមកំបាំងមុខនោះទៅ

ក-ភាគីដែលអវត្តមាននោះ ទៅលំនៅឋាន ទីសំណាក់ (បើគ្មានលំនៅឋាន)ទីកន្លែងអាជីវកម្ម ឬទីស្នាក់ការរបស់ជននោះ ដោយឱ្យសាមីខ្លួនផ្តិតមេដៃទទួល និងចុះថ្ងៃ ខែ ឆ្នាំ ប្រគល់ និងទទួលឱ្យបានច្បាស់លាស់ព្រមទាំងប្រាប់ពីសិទ្ធិរបស់គេក្នុងការប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

ខ-ប្រសិនបើមិនបានជួបសាមីខ្លួនដែលអវត្តមាន នៅទីកន្លែងដូចក្នុងចំណុច(ក)ខាងលើទេ មន្ត្រីទទួលបន្ទុកការបញ្ជូន អាចប្រគល់សេចក្តីជូនដំណឹងពីសាលក្រមកំបាំងមុខនោះទៅឱ្យសមាជិកណាម្នាក់នៅក្នុងគ្រួសារ

នោះដែលមានវត្តមាន ហើយដែលមានការយល់ដឹងសមរម្យក្នុងការទទួលសេចក្តីជូនដំណឹងនោះ ហើយឱ្យបុគ្គលនោះផ្តិតមេដៃទទួល និងបញ្ជាក់ឈ្មោះ អាយុ និងឋានៈក្នុងគ្រួសាររបស់បុគ្គលនោះជាមួយនឹងសាមីខ្លួនដែលអវត្តមាននោះឱ្យបានច្បាស់លាស់ ។

គ-ប្រសិនបើការបញ្ជូនសេចក្តីជូនដំណឹងពីសាលក្រមកំបាំងមុខនោះ មិនអាចសម្រេចបានដោយសារភាគីអវត្តមាននោះបានផ្លាស់ប្តូរទីកន្លែងដែលត្រូវបញ្ជូនខាងលើ ហើយទោះបីជាមន្ត្រីទទួលបន្ទុកការបញ្ជូនបានខិតខំប្រឹងប្រែងធ្វើការស្រាវជ្រាវរកយ៉ាងណាក៏ដោយក៏នៅតែរកមិនឃើញនោះ សេចក្តីជូនដំណឹងពីសាលក្រមកំបាំងមុខនោះត្រូវយកទៅៈ

១-បិទនៅលំនៅឋានឬទីសំណាក់(បើពុំមានលំនៅឋាន)ចុងក្រោយបង្អស់របស់ភាគីអវត្តមាននោះ០១ច្បាប់

២-បិទនៅទីស្នាក់ការ ឃុំ ឬ សង្កាត់ នៃលំនៅឋាន ឬ ទីសំណាក់ របស់ភាគីអវត្តវត្តមាននោះ០១ ច្បាប់ ។

ក្នុងការអនុវត្តចំណុចទី១ និងទី២នេះ មន្ត្រីទទួលបន្ទុកការបញ្ជូនត្រូវសរសេរក្នុងលិខិតជូនដំណឹងដោយបញ្ជាក់ឱ្យបានច្បាស់លាស់អំពីការផ្លាស់ប្តូរលំនៅឋាន របស់អ្នកត្រូវទទួលនិងការបញ្ជូននោះជូនទៅតុលាការហើយក៏ត្រូវមានសាក្សីពីររូបទៀតធ្វើជាសាក្សីផងដែរ ។

៣-ចុះផ្សាយតាមវិទ្យុជាតិ និងតាមសារព័ត៌មានផ្លូវការ ។

ឃ-បើក្នុងករណី ជនដែលត្រូវទទួលការបញ្ជូននៅក្នុងចំណុច “ ក ” និង “ ខ ” ខាងលើមិនព្រមទទួលសេចក្តីជូនដំណឹងពីសាលក្រមកំបាំងមុខនោះទេ មន្ត្រីទទួលបន្ទុកការបញ្ជូនត្រូវកំណត់ហេតុបញ្ជាក់អំពីហេតុការណ៍នោះឱ្យបានច្បាស់លាស់ជូនទៅតុលាការ ហើយត្រូវមានសាក្សីពីររូបធ្វើជាសាក្សីផងដែរ ។

ង-ក្នុងករណីមិនបានជួបសាមីខ្លួនអ្នកទទួល ឬសមាជិកគ្រួសារណាម្នាក់ទេ ប៉ុន្តែអាជ្ញាធរឃុំ-សង្កាត់បានបញ្ជាក់ថា ឈ្មោះនេះកំពុងរស់នៅជាអចិន្ត្រៃយ៍នៅលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬ ទីស្នាក់ការនោះមន្ត្រីទទួលបន្ទុកការបញ្ជូន គប្បីខិតខំព្យាយាមដោយសហការជាមួយអាជ្ញាធរ ឃុំ-សង្កាត់ ស្វះស្វែងឱ្យបានជួបអ្នកត្រូវទទួលនោះដើម្បីអនុវត្តតាមចំណុច ក-ខ និង ឃ ខាងលើ ។

ករណីស្វះស្វែងនេះ មិនទទួលបានលទ្ធផលមន្ត្រីទទួលបន្ទុកការបញ្ជូនត្រូវយកលិខិតជូនដំណឹងនោះ

១-ទៅបិទនៅលំនៅឋាន របស់អ្នកត្រូវទទួលការបញ្ជូន០១ ច្បាប់ ។

២-បិទនៅទីស្នាក់ការឃុំ សង្កាត់ នៃលំនៅឋាន ឬ សំណាក់របស់ភាគីអវត្តមាននោះ០១ច្បាប់ ហើយត្រូវធ្វើកំណត់ហេតុបញ្ជាក់អំពីហេតុការណ៍នោះឱ្យបានច្បាស់លាស់ជូនទៅតុលាការ ហើយត្រូវមានសាក្សីពីររូបធ្វើជាសាក្សីផងដែរ ។

## II-អំពីគោលការណ៍សម្រាប់អនុវត្ត ដោះស្រាយសំណុំរឿងក្តីដែលរកចុងចម្លើយមិនឃើញ

ចំពោះសំណុំរឿងក្តី ដែលតុលាការបានទទួលពាក្យបណ្តឹងពីដើមចោទហើយ តែតុលាការមិនអាចកោះអញ្ជើញ ជូនដំណឹងទៅភាគីចុងចម្លើយបានចាប់តាំងពីតុលាការផ្តើមអនុវត្តនីតិវិធីដំបូងដោយសារតុលាការពុំអាចរកឃើញលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬទីស្នាក់ការ របស់ចុងចម្លើយនោះ តុលាការមិនត្រូវប្រញាប់ប្រញាលធ្វើការសម្រេចសេចក្តីកំបាំងមុខចុងចម្លើយឡើយ គឺតុលាការត្រូវបង្គាប់ឱ្យដើមចោទប្រឹងប្រែងធ្វើការស្រាវជ្រាវស្វែងរកអាសយដ្ឋានចុងចម្លើយឱ្យអស់ពីលទ្ធភាព ដើម្បីឱ្យចុងចម្លើយបានដឹង និងអាចអះអាងតបត ឬដាក់មធ្យោបាយការពារខ្លួនចំពោះការទាមទាររបស់ដើមចោទនោះ ។ ក្នុងករណីស្វះស្វែងរកអាសយដ្ឋានរបស់ចុងចម្លើយតាមគ្រប់មធ្យោបាយហើយ ប៉ុន្តែនៅតែរកមិនឃើញទៀតនោះ តុលាការមិនគប្បីដាក់រឿងក្តីនោះជំនុំជម្រះសម្រេចសេចក្តីកំបាំងមុខចុងចម្លើយទេ គឺតុលាការត្រូវសម្រេចបង្អង់រឿងនោះទុកមួយអន្លើសិន តាមដីកាបង្អង់រឿងទុកមួយអន្លើដើម្បីរង់ចាំដើមចោទស្វែងរកអាសយដ្ឋាន របស់ចុងចម្លើយឃើញពិតប្រាកដ ។

ក្នុងករណីដើមចោទ និងចុងចម្លើយបានចូលរួមនៅក្នុងដំណាក់កាលដំបូង នៃនីតិវិធីរបស់តុលាការហើយ នោះមានន័យថា ចុងចម្លើយមានឈ្មោះ និង អាសយដ្ឋានច្បាស់លាស់ ហើយបានទទួល ឬរឹងទទឹងពុំព្រមទទួលដីកាកោះនោះតុលាការអាចចាត់ការតាមនីតិវិធីក្នុងការដោះស្រាយរឿងក្តីបន្តទៅតាមច្បាប់ ។

គោលការណ៍កំណត់អំពីការអនុវត្តប្រគល់លិខិតជូនដំណឹងពីសាលក្រមកំបាំងមុខនេះ ក៏ត្រូវយកទៅធ្វើជាគោលការណ៍សម្រាប់អនុវត្ត ចំពោះការប្រគល់ដីកាកោះ និងការជូនដំណឹងអំពីសេចក្តីសម្រេចផ្សេងទៀតផងដែរ ។

ក្រោយពីបានទទួលសារាចរណែនាំនេះ ក្រសួងយុត្តិធម៌សង្ឃឹមថា លោក-លោកស្រី ជាប្រធានតុលាការ និងព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង នឹងធ្វើការផ្សព្វផ្សាយដល់មន្ត្រីរាជការទាំងអស់ក្នុងអង្គភាពរៀងៗខ្លួនដើម្បីអនុវត្តឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៥

**រដ្ឋមន្ត្រី**

**អង្គ វង្សវឌ្ឍានា**

<u>ចម្លងជូន</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
-ដើម្បីជូនជ្រាប
-តុលាការកំពូល និង មហាអយ្យការ
-សាលាឧទ្ធរណ៍ និង មហាអយ្យការ
-ដើម្បីជូនជ្រាប និង អនុវត្ត